ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

និយ័តករបរធនបាលកិច្ច
TRUST REGULATOR

**និយ័តករបរធនបាលកិច្ច**
លេខ: ០១៥/២៤ ន.ប.ធ./ស.ជ.ណ.

ថ្ងៃពុធ ១១កើត ខែ ផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២០ ខែ មីនា ឆ្នាំ២០២៤

# សេចក្តីជូនដំណឹង
## ស្តីពី
## ការផ្តល់ការទទួលស្គាល់ក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យបរធនបាលកិច្ច

**និយ័តករបរធនបាលកិច្ច (ន.ប.ធ.)** មានកិត្តិយសសូមជម្រាបជូនដំណឹងដល់បរធនបាល បរធនបាលទាយក ឬអ្នកផ្តល់វិភាគទានបរធនបាលកិច្ច បុគ្គលផ្តល់សេវាពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច និងសាធារណជនទាំងអស់ មេត្តាជ្រាបថា÷ ក្រុមហ៊ុន **ឌីឡូយធ៍ (ខេមបូឌា) ខូ អិលធីឌី (Deloitte (Cambodia) Co., Ltd.)** ទទួលបានការទទួលស្គាល់ពី **ន.ប.ធ.** ជាក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យបរធនបាលកិច្ច ដោយបានបំពេញតាមលក្ខខណ្ឌតម្រូវគ្រប់គ្រាន់តាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមានក្នុងវិស័យបរធនបាលកិច្ច។

បរធនបាល បរធនបាលទាយក ឬអ្នកផ្តល់វិភាគទានបរធនបាលកិច្ច បុគ្គលផ្តល់សេវាពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច និងសាធារណជនទាំងអស់ ដែលមានបំណងប្រើប្រាស់សេវាសវនកម្មក្នុងវិស័យបរធនបាលកិច្ចអាចទំនាក់ទំនងទៅកាន់ក្រុមហ៊ុនដែលមានឈ្មោះខាងលើ។ សូមបញ្ជាក់ថា÷ក្រុមហ៊ុន **ឌីឡូយធ៍ (ខេមបូឌា) ខូ អិលធីឌី** ជាក្រុមហ៊ុនទី**៨** ដែលទទួលបានការទទួលស្គាល់ពី **ន.ប.ធ.** ដើម្បីផ្តល់សេវាសវនកម្មក្នុងវិស័យបរធនបាលកិច្ច។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម បរធនបាល បរធនបាលទាយក ឬអ្នកផ្តល់វិភាគទានបរធនបាលកិច្ច បុគ្គលផ្តល់សេវាពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច និងសាធារណជនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន។

**និយ័តករបរធនបាលកិច្ច**

អគារ ១៦៨F (ជាន់ទី៨) ផ្លូវ ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Building 168F (8th Floor), Street 598, Sangkat Chrang Chamres 1, Khan Russey Keo,
Phnom Penh, Kingdom of Cambodia
ទូរស័ព្ទ : (+៨៥៥)២៣-២៣៧-៨៨៨
សារអេឡិចត្រូនិច : info@trustregulator.gov.kh
គេហទំព័រ : www.trustregulator.gov.kh